# ថ្ងៃដែលមេធាវីមានការពេញចិត្តបំផុត


**ដោយ ឡូរ៉ា ម៉ាក់ដូណល់**

**ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩**

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*


ប្រជាជនកម្ពុជាមួយក្រុមធំបានមកដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយរថយន្តក្រុងនាពេលព្រឹកនេះ ។ ប្រជាជនទាំងនោះបាននាំគ្នាថតរូបនៅខាងក្រៅអង្គជំនុំជម្រះ និងមានសេចក្តីត្រេកអរដែលបានចូលរួមតាមដានអង្គជំនុំជម្រះសេចក្តីប្រឆាំងនឹង ឌុច ។ ប្រជាជនកម្ពុជាទាំងអស់បានតាមដានជម្លោះនីតិវិធីស្ទើរតែពេញមួយថ្ងៃ ដូច្នេះខ្ញុំគិតថា ពួកគេនឹងវិលត្រឡប់ទៅវិញទាំងចម្ងល់ ។

នៅក្នុងអង្គជំនុំជម្រះសេចក្តីនាពេលព្រឹក អង្គជំនុំជម្រះសាលាដំបូងបានបន្តចោទសួរសំណួរទៅកាន់សាក្សីជំនាញគឺ ក្រេក អេតឆេសាន់ ជាអ្នកប្រាជ្ញជាតិអាមេរិកដែលធ្វើការសិក្សាស្រាវជ្រាវពីរបបកម្ពុជាប្រជាធិបតេយ្យអស់រយៈពេលបីទសវត្សរ៍ ។ ក្នុងកិច្ចឆ្លើយតបនឹងសំណួររបស់ចៅក្រម ខាត-រ៉ាយថ៍, ក្រេក អេតឆេសាន់ បានរាយការណ៍ថា តាមពិត«ការបោសសម្អាត»ដែលមានលក្ខណៈរាលដាលបានកើតមានឡើងទូទាំងកងទ័ពបដិវត្តន៍របស់កម្ពុជាគ្រប់កងពលទាំងអស់ ។ ដូចដែលបានបង្ហាញនៅក្នុងឧទាហរណ៍ជាច្រើននេះ ក្រេក អេតឆេសាន់ បានកត់សម្គាល់ថា កងទ័ពយោធាចំនួន៨៥៥នាក់ត្រូវបានបោសសម្អាតពីកងពលលេខ៣១០ ដែលចាប់ផ្តើមកើតឡើងនៅខែធ្នូ ឆ្នាំ១៩៧៦ និងបន្តរហូតមកដល់ឆ្នាំ១៩៧៧ ហើយយ៉ាងហោចណាស់កងទ័ពយោធាចំនួន៤០៦នាក់ត្រូវបានបោសសម្អាតចេញពីកងពលលេខ៧០៣ ក្នុងអំឡុងឆ្នាំ១៩៧៧ និង១៩៧៨ ។ លោកបានឆ្លើយប្រាប់ថា ស្របពេលដែលកងទ័ពយោធាខ្លះត្រូវបានសម្លាប់នៅក្នុងអង្គភាពរបស់ខ្លួន ឬក៏បញ្ជូនទៅកន្លែងធ្វើការងារពលកម្មដោយបង្ខំនោះ កងទ័ពយោធាជាច្រើននាក់ទៀតត្រូវបានបញ្ជូនទៅមន្ទីរស-២១ ។ លោកបានចាត់ទុករបាយការណ៍របស់អនុលេខាកងពលលេខ៥០២ដែលផ្ញើទៅឲ្យ សុន សេន ដែលនិយាយថា«មនុស្សគ្មានប្រយោជន៍»ចំនួន៥០នាក់ត្រូវបានបញ្ជូនទៅមន្ទីរស-២១នោះ ជាភស្តុតាងដែលបង្ហាញឲ្យឃើញថា មេបញ្ជាការកងពលនីមួយៗបានដឹងពីដំណើរការប្រតិបត្តិការរបស់មន្ទីរស-២១ និងមានចូលរួមយ៉ាងសកម្មក្នុងការបញ្ជូនមនុស្សទៅកាន់មន្ទីរស-២១ ។ ក្រេក អេតឆេសាន់ បានបន្តរៀបរាប់ថា នេះគឺជាការអនុវត្តជាទូទៅមួយ សម្រាប់អ្នកទោសដែលត្រូវបញ្ជូនទៅមន្ទីរស-២១ត្រូវតែអមជាមួយ

សំបុត្រមួយច្បាប់ចេញពីអនុលេខាកផលដែលបានអះអាងថា អ្នកទោសនោះមានជាប់ពាក់ព័ន្ធជាមួយនឹងអ្នករួមគំនិតក្បត់ដែលមាននៅក្នុងចម្លើយសារភាព ។ លោកបានបន្ថែមទៀតថា ការចាប់ខ្លួនដែលមានលក្ខណៈរាលដាលខ្លាំងបានកើតមានឡើងនៅក្នុងជួរមន្ត្រីរដ្ឋាភិបាល ហើយបានលើកឡើងពីរបាយការណ៍របស់មន្ត្រីរដ្ឋាភិបាលមួយរូបដែលថា ការប្រតិបត្តិការផ្សារប្រចាំថ្ងៃរបស់មន្ត្រីនោះមានភាពលំបាកដោយសារតែមានការកាត់បន្ថយចំនួនបុគ្គលិកដល់ទៅ១៥ភាគរយ ។

បន្ទាប់មកដំណើរការនីតិវិធីត្រូវបានផ្អាកដោយសារតែមានការជំទាស់ពី ហ្វ្រង់ស៊័រ រូ មេធាវីការពារក្តីអន្តរជាតិ ។ ក្នុងកិច្ចឆ្លើយតបនឹងសំណួរចៅក្រម ខាត់រ៉ាយថ៍ ទាក់ទិននឹងប្រភពផ្សេងទៀតដែលមន្ទីរស-២១ទទួលបានអ្នកទោសមកឃុំឃាំងនោះ ក្រេក អេតឆេសាន់ បានផ្តល់ការវិភាគដ៏លម្អិតខ្លះៗពីមន្ទីរស-២១ ហើយបានលើកឡើងពីឯកសារមួយចំនួននៅក្នុងសំណុំរឿងដែលមិនត្រូវបានដកស្រង់ចេញពីរបាយការណ៍ឆ្នាំ២០០៧ របស់លោកដែលមានចំណងជើងថា «សេចក្តីសន្និដ្ឋានពីឋានានុក្រមនៃរបបកម្ពុជាប្រជាធិបតេយ្យ» ។ ដោយផ្អែកលើសេចក្តីបង្គាប់របស់ចៅក្រម ហ្វ្រង់ស៊័រ រូ បានអះអាងថា ក្រេក អេតឆេសាន់ មានបំណងពិភាក្សាពីប្រធានបទផ្សេងទៀតដូចជា អង្គភាព និងប្រតិបត្តិការនៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមិនមែនមន្ទីរស-២១ ។ ដើម្បីរៀបចំខ្លួនឲ្យបានរួចរាល់ជាស្រេចសម្រាប់ដំណើរការនីតិវិធីមួយៗ រូ អះអាងថា មេធាវីការពារក្តីត្រូវតែផ្តល់ជូនជាព័ត៌មានថា សាក្សីជំនាញនឹងធ្វើកសិណសាក្សីតែពីមន្ទីរស-២១ និងផ្តល់ជារបាយការណ៍ដ៏ជំនាញបន្ទាប់បន្សំដែលមានផ្ទុកនូវការវិភាគរបស់ ក្រេក អេតឆេសាន់ តែប៉ុណ្ណោះ ។ ជាមួយគ្នានេះ រូ ក៏បានបដិសេធថា ការប្រើប្រាស់ឯកសារពីរ ដែលមិនបានបកប្រែជាភាសាបារាំងនោះត្រូវតែធ្វើការបកប្រែជាប្រញាប់ ។ បន្ទាប់ពីរយៈពេលមួយ ម៉ោងនៃការគូសបញ្ជាក់លើសំណួររបស់ចៅក្រម ខាត់រ៉ាយថ៍ និងការចូលរួមជាយោបល់ពីសំណាក់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីរួមជាមួយនឹងការឈប់សម្រាករយៈពេល«កន្លះម៉ោង»ដែលបន្តរហូតដល់៤៥នាទីក្រោយមក ចៅក្រមបានប្រកាសផ្អាកដំណើរការនីតិវិធីសម្រាប់អាហារថ្ងៃត្រង់ជាបន្តទៀត ។

ក្រោយពីឈប់សម្រាកអាហារថ្ងៃត្រង់មក លោកប្រធានចៅក្រម និល ណុន បានប្រកាសថា អង្គជំនុំជម្រះមិនធ្វើការកំណត់លើវិសាលភាពរបាយការណ៍របស់សាក្សីជំនាញឡើយ ហេតុដូច្នេះ ចៅក្រម និងភាគីទាំងអស់មានសិទ្ធិចោទសួរសាក្សីជំនាញនូវសំណួរសំខាន់ៗបាន ។ ដូចគ្នាដែរ សាក្សីជំនាញមិនត្រូវបានកំណត់ឲ្យឆ្លើយទៅតាមសេចក្តីសន្និដ្ឋានជាលាយល័ក្ខអក្សរ ឬរបាយការណ៍ដើមរបស់ខ្លួនរហូត

ឡើយ ។ បន្ថែមលើនេះ យោងតាមនីតិវិធីទូទៅ ឯកសារទាំងអស់ត្រូវតែបានបកប្រែជាភាសាផ្លូវការបីរបស់តុលាការ (ខ្មែរ បារាំង និងអង់គ្លេស) ប៉ុន្តែអង្គជំនុំជម្រះនឹងទទួលយកឯកសារជាភាសាខ្មែរ និងភាសាផ្លូវការរបស់តុលាការមួយទៀត ប្រសិនបើចាំបាច់ ។ ការធ្វើបែបនេះគឺដោយសារតែសេវាកម្មបកប្រែនៅមានកម្រិតនៅឡើយ ហើយយោងទៅតាមវិធាន២១នៃវិធានផ្ទៃក្នុងស្តីពីកាតព្វកិច្ចរៀបចំដំណើរការអង្គជំនុំជម្រះឲ្យទាន់ពេលវេលា ។ អង្គជំនុំជម្រះផ្តល់ពេលឲ្យមេធាវីការពារក្តីឲ្យធ្វើសេចក្តីសន្និដ្ឋានលើឯកសារដែលមិនទាន់បកប្រែជាភាសាបារាំងរហូតដល់ព្រឹកស្អែក ហើយបានសម្រេចថា រាល់ភាគីទាំងអស់មិនត្រូវធ្វើការយោងលើខ្លឹមសាររបស់ឯកសារទាំងពីរនោះទេ ។

ចៅក្រម ខាតរ៉ាយច៍ បានបន្តសួរសំណួរ ក្រេក អេតឆេសាន់ ។ មុននឹងសាក្សីជំនាញអាចបញ្ចប់ចម្លើយរបស់ខ្លួន ប្រ៉ាង់ស៊័រ រូ បានបញ្ចេញនូវយោបល់មិនពេញចិត្តជាថ្មីម្តងទៀត ដោយសារតែម្តងនេះសាក្សីជំនាញបានកំពុងប្រើប្រាស់ឆាតក្រាហ្វិកដែលមិនមានក្នុងសំណុំរឿង ដើម្បីឆ្លើយនឹងសំណួរទាក់ទិននឹងតួរលេខដ៏ខ្ពស់នៃកម្មាភិបាលថ្នាក់ស្រុកដែលត្រូវបានបញ្ជូន ទៅមន្ទីរស-២១ក្នុងឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ។ ក្រេក អេតឆេសាន់ បានរៀបរាប់ថា មន្ទីរស-២១គឺជាមន្ទីរសន្តិសុខតែមួយគត់ដែលមានអំណាចឃុំឃាំងមនុស្សទូទៅក្នុងប្រទេសទាំងមូល និងសួរចម្លើយសមាជិកគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម ។ មន្ទីរស-២១ ក៏មានលក្ខណៈខុសប្លែកពីមន្ទីរសន្តិសុខដទៃទៀតត្រង់ថា មន្ទីរស-២១ ទទួលឃុំឃាំងអ្នកទោសដែលមានឋានៈខ្ពស់បំផុត ឬអ្នកទោសសំខាន់ៗ រួមមានកម្មាភិបាលគ្រប់គ្រងភូមិភាគ កម្មាភិបាលតាមវិស័យផ្សេងៗ និងថ្នាក់ដឹកនាំតាមស្រុក រួមទាំងមេដឹកនាំរដ្ឋាភិបាលផងដែរ ។

ក្រេក អេតឆេសាន់ បានឆ្លើយប្រាប់អង្គជំនុំជម្រះថា ក្នុងអំឡុងពេលដែល ឌុច មិនទាន់ក្លាយជាប្រធានមន្ទីរស-២១ នោះការដោះលែងអ្នកទោសចេញពីគុកគឺមិនបានកើតឡើងជាទូទៅទេ ។ ប៉ុន្តែនៅពេលដែល ឌុច ក្លាយជាប្រធាន នោះការដោះលែងអ្នកទោសកាន់តែកម្រកើតមានឡើងណាស់ ។ សាក្សីជំនាញបានលើកឡើងថា ឯកសារថ្មីៗដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជាគូសបញ្ជាក់ថាមានការដោះលែងខ្លះដែរ ។ លោកបាននិយាយថាបើទោះបីជាឯកសារទាំងអស់នេះមិនមានជាភាសាបារាំងក៏ដោយ ក៏លោកសង្ឃឹមថា មេធាវីការពារក្តីនឹងយល់ស្របតាមឯកសារយោងរបស់លោកបើពិចារណាពីកត្តាដាក់បន្ទុករបស់ឯកសារទាំងនេះ ។ អេលីហ្សាប៉ែត រ៉ាបេសាន់ជ្រា តាណា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានជំទាស់នឹងសេចក្តីសន្និដ្ឋាននេះដោយអះអាងថាវាធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះ ហើយបានសួរថា តើលោកស្រីអាចនឹងបដិសេធលើភស្តុតាងនេះយ៉ាងដូចម្តេចទៅ បើភស្តុ-

តាំងនោះមិនត្រូវបានណែនាំឲ្យបានច្បាស់លាស់បែបនេះនោះ ។ ក្នុងកិច្ចឆ្លើយតបនឹងសំណួរមួយរបស់ចៅក្រម ឡាវែន៍ សាក្សីជំនាញបានគូសបញ្ជាក់ថា ប្រសិនបើយើងដាក់មន្ទីរស-២៨ឲ្យនៅក្រោមការគ្រប់គ្រងរបស់មន្ទីរស-២១ ដោយសារតែមន្ទីរស-២៨ក៏នៅក្រោមការគ្រប់គ្រងរបស់ ឌុច ដែរនោះយើងសង្កេតឃើញថា ការដោះលែងអ្នកទោសបានកើតឡើងជាទូទៅច្រើនជាងនៅមន្ទីរស-២១ ។ ជំរុំកសាងខ្លួនដែលមានឈ្មោះថា មន្ទីរស-២៨នេះបានបែងចែកអ្នកទោសជាក្រុមដូចខាងតទៅ : ១) អ្នកទោសកម្រិតស្រាល ២) អ្នកទោសកម្រិតធ្ងន់ និង៣) អ្នកទោសកម្រិតកណ្តាល ដែលចាំបាច់ត្រូវកំណត់ថា ទោសរបស់អ្នកទោសនោះធ្ងន់ ឬស្រាល ។ ក្រេក អេតឆេសាន់ បានពន្យល់រៀបរាប់ថា ដោយសារតែលក្ខខណ្ឌរស់នៅមិនអំណោយផល អ្នកទោសជាច្រើននាក់ស្លាប់នៅមន្ទីរស-២៨ ប៉ុន្តែជាញឹកញាប់ អ្នកទោសកម្រិតស្រាលត្រូវបានចាត់ទុកថា "បានកសាងខ្លួនតាមរយៈការងារពលកម្ម" បន្ទាប់មកក៏ត្រូវដោះលែង ។

ជាចុងក្រោយ ក្រេក អេតឆេសាន់ បានពន្យល់ថា អ្នកទោសភាគច្រើនត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១ ក្រោយពីត្រូវបានឃុំខ្លួននៅតាមអង្គភាពរបស់ខ្លួន ។ ទម្រង់មិនជាទូទៅជាច្រើន រួមមានការចាប់ខ្លួននៅក្រៅអង្គភាពដែលធ្វើឡើងដោយបុគ្គលិកមន្ទីរស-២១ និងការចាប់ខ្លួនមេដឹកនាំបក្សជាន់ខ្ពស់ក្នុងអង្គភាពបានប្រព្រឹត្តឡើង ដោយការបោកបញ្ឆោតនាំមកកាន់ការិយាល័យធ្វើការរបស់ ឌុច ហើយអ្នកទាំងនោះមិនដឹងរឿងអ្វីទាំងអស់ ។ នៅពេលដែលលោកប្រធានចៅក្រមបានប្រគល់ភារកិច្ចឲ្យសហព្រះរាជអាជ្ញាសួរទៅកាន់សាក្សីជំនាញ ស្រាប់តែបញ្ហានីតិវិធីចម្បងមួយបានផ្អាកដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ ។ យោងតាមវិធាន៨៧នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក អង្គជំនុំជម្រះត្រូវតែចេញសេចក្តីសម្រេចដោយផ្អែកលើសំណុំរឿងដែល"ដាក់ចំពោះអង្គជំនុំជម្រះ" ហើយតម្រូវឲ្យភស្តុតាងនោះ"ធ្វើការសង្ខេប ឬអាននៅក្នុងអង្គជំនុំជម្រះ" ។ អេឡិចសាន់ឌឺ ប៊ើត បានស្នើសុំសេចក្តីបង្គាប់ពីអង្គជំនុំជម្រះសម្រាប់វិធីសាស្រ្តដ៏ល្អដើម្បីដាក់ឯកសារចំនួន១៤៨ ដែលដកស្រង់ចេញពីរបាយការណ៍ជំនាញរបស់ ក្រេក អេតឆេសាន់ ចំពោះមុខអង្គជំនុំជម្រះតាមរយៈការអាន ឬក៏សង្ខេបឯកសារទាំងអស់នោះដែលអាចចំណាយពេលជាច្រើនថ្ងៃឬសប្តាហ៍ ដោយអាស្រ័យតាមវិធីសាស្រ្តដែលនឹងត្រូវសម្រេចនោះ ។ អេឡិចសាន់ឌឺ ប៊ើត បានស្នើសុំឲ្យធ្វើការសង្ខេបឯកសារទាំង១៤៨ នោះដោយដាក់វាជាប្រភេទ និងដាក់បញ្ចូលឯកសារនោះទៅក្នុងបញ្ជីឧបសម្ព័ន្ធដោយខ្លួនឯង ។ ដើម្បីធានាឲ្យបាននូវការជំនុំជម្រះសេចក្តីប្រកបដោយយុត្តិធម៌ សេចក្តីជំទាស់ត្រូវបានអនុញ្ញាតឲ្យធ្វើឡើងទាក់ទិននឹងបញ្ហាការរៀបចំឯកសារជាលក្ខណៈបុគ្គលនេះ ។ ដោយផ្តល់ឱកាសធ្វើការឆ្លើយតបនឹងបញ្ហានេះ មេធាវីការពារក្តី

ហ្វ្រង់ស៊័រ រូ បានចោទប្រកាន់សហព្រះរាជអាជ្ញាថា បានបង្កឲ្យតុលាការជួបបញ្ហាគានគឹងដោយសារតែឯកសារ«មិនមានប្រយោជន៍»ទាំងអស់នេះ ដែលអាចបណ្ដាលឲ្យមាន«ការពន្យារពេលដោយគ្មានស្មារតីប្រុងប្រយ័ត្ន» ដល់ដំណើរការនីតិវិធីរបស់តុលាការ ។ រូ បានណែនាំថា តុលាការគួរតែអនុវត្តទៅតាមវិធាន៨៥នៃវិធានផ្ទៃក្នុង ដែលលោកប្រធានចៅក្រមមានសិទ្ធិអំណាចសម្រេច«មិនរៀបចំឲ្យមានដំណើរការនីតិវិធីដែលពន្យារដំណើរការជំនុំជម្រះសេចក្ដី ហើយដែលមិនមានប្រយោជន៍ដួយដល់ការស្វែងរកការពិត» ។ រូ បានបន្តទទូចសុំឲ្យសហព្រះរាជអាជ្ញាត្រូវតែបង្ខំឲ្យជ្រើសយកតែឯកសារសំខាន់ៗតែប៉ុណ្ណោះ ។ ប៉ុន្តែ អេឡិចសាន់ឌឺ បេិត បានឆ្លើយតបថា សាក្សីជំនាញបានជ្រើសរើសឯកសារសំខាន់ចំនួន១៨៨ នេះចេញពីឯកសាររាប់ពាន់ផ្សេងទៀត ។ ចៅក្រមហាក់បីដូចជាមានភាពច្របូកច្របល់បន្តិច ហើយក៏សុំពេលធ្វើការពិភាក្សាមួយរយៈខ្លី ក្រោយមកក៏ប្រកាសថា ដំណើការនីតិវិធីសម្រាប់ថ្ងៃស្អែកនឹងចាប់ផ្ដើមយឺតបន្តិច ដើម្បីឲ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ចៅក្រមធ្វើការដោះស្រាយបញ្ហានីតិវិធីដ៏ចម្បងនេះ ។

ថ្ងៃនេះ ភាគីទាំងអស់បានបង្ហាញនូវចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើដំណោះស្រាយដែលសមហេតុផល ទាក់ទិននឹងបញ្ហានីតិវិធីទាំងបញ្ហាតូចតាច និងមិនសូវតូចតាច ។ យ៉ាងណាមិញ ការពិភាក្សាវែកញែកពីបញ្ហានីតិវិធីអាចនឹងធ្វើឲ្យដំណើរការនីតិវិធីមានភាពយឺតយ៉ាវ ។